**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ០៤ ប្រក.ឌ៣

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា
## ស្តីពីការផ្អាកការផ្តល់សេវារដ្ឋបាលមួយចំនួនរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
**(ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០២៣)**

ក្នុងរយៈពេលថ្មីៗនេះ, ព័ត៌មានមួយចំនួន បានផ្សព្វផ្សាយអំពីការតម្រូវឱ្យស្នើសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្ម និងបន្តសុពលភាពអាជីវកម្ម នៅការិយាល័យច្រកចេញ-ចូលតែមួយ នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលការណ៍នេះបានបង្កឱ្យមានការព្រួយបារម្ភ ក្នុងចំណោម ប្រជាពលរដ្ឋ ដែលបាន និងកំពុងប្រកបអាជីវកម្ម, មុខរបរ និង ការងារ នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។

បន្ទាប់ពីបានឃើញការផ្សព្វផ្សាយនេះ, ក្នុងគោលដៅសម្រួលដល់ការប្រកបអាជីវកម្ម, មុខរបរ និង ការងារ ក៏ដូចជាការលើកកម្ពស់នូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ, **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់ការណែនាំដ៏ខ្ពង់ខ្ពស់ ឱ្យមានការផ្អាកការផ្តល់សេវារដ្ឋបាលមួយចំនួន របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ពាក់ព័ន្ធនឹងការបំពេញបែបបទធ្វើអាជីវកម្ម ដែលកំណត់ដោយប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម ៖

**ក. វិស័យវប្បធម៌ និងវិចិត្រសិល្បៈ**

១. អាជីវកម្មសិល្បៈសូនរូប
- ទីតាំងផលិត និងលក់ចម្លាក់ ពុម្ពស៊ីម៉ងត៍
- ជាងគំនូរ

២. អាជីវកម្មកាត់សក់ អ៊ុតសក់ លម្អក្រចក និងសម្អាងការ (ហាង)
- កាត់សក់បុរស (ចាប់ពី ២ កៅអី ទៅ ៤ កៅអី)
- កាត់សក់បុរស (ចាប់ពី ៥ កៅអី ឡើងទៅ)
- អ៊ុតសក់ កាត់សក់ លម្អក្រចក (ចាប់ពី ២ កៅអី ទៅ ៤ កៅអី)
- អ៊ុតសក់ កាត់សក់ លម្អក្រចក (ចាប់ពី ៥ កៅអី ឡើងទៅ)
- សម្អាងការ (តម្លៃក្រោម ៥០០ ដុល្លារអាម៉េរិក)
- សម្អាងការ (តម្លៃចាប់ពី ៥០០ ដុល្លារអាម៉េរិក ដល់ក្រោម ១.០០០ ដុល្លារអាម៉េរិក)

**ខ. វិស័យអប់រំ យុវជន និងកីឡា**

- អាជីវកម្មលក់សម្ភារកីឡា រួមទាំងការធ្វើសុពលភាពឡើងវិញ

**គ. វិស័យទេសចរណ៍**

- ភោជនីយដ្ឋាន និងអាហារដ្ឋានក្នុងស្រុក
- តូបលក់អាហារ
- ហាងលក់គុយទាវ កាហ្វេ
- ម៉ូតូឌុបទេសចរណ៍
- ម៉ូតូជួលទេសចរណ៍
- រ៉ឺម៉កម៉ូតូដឹកទេសចរណ៍

**ឃ. វិស័យឧស្សាហកម្ម និងសិប្បកម្ម និងវិស័យរ៉ែ និងថាមពល**

១. ចុះបញ្ជីសិប្បកម្ម

- ផលិតជើងតាង ៣ង លូ ឥដ្ឋការ៉ូ
- ធ្វើទៀន ធូប

២. ថាមពល

- ដំឡើងម៉ាស៊ីនអគ្គិសនីសម្រាប់ធ្វើសេវាកម្មបញ្ចូលអាគុយ ដែលមានកម្លាំងមិនលើសពី ២៥ គីឡូវ៉ាត់

៣. សេវាកម្ម

- ជួសជុលគ្រឿងអគ្គិសនីអេឡិចត្រូនិក
- លាងរថយន្ត ម៉ូតូ
- លាងម៉ូតូ

**ង. វិស័យពាណិជ្ជកម្ម**

- លិខិតអនុញ្ញាតធ្វើអាជីវកម្ម សេវាកម្មពាណិជ្ជកម្ម

**ច. វិស័យកសិកម្ម**

- លិខិតអនុញ្ញាតធ្វើអាជីវកម្មលក់ជី ថ្នាំ ពូជ សម្ភារកសិកម្ម ។

រាជរដ្ឋាភិបាលកម្ពុជា តែងផ្តល់អាទិភាពខ្ពស់បំផុត ក្នុងការបង្កលក្ខណៈងាយស្រួល, ព្រមទាំងផ្តល់ប្រយោជន៍, ថែបំប៉ន និងលើកកម្ពស់ការយល់ដឹង ដល់អ្នកប្រកបអាជីវកម្ម, មុខរបរ និងការងារ ដែលស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។ ជាក់ស្តែង, រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការនូវកម្មវិធីជំនួយសង្គមជាច្រើន ដើម្បីចូលរួមចំណែក ក្នុងការលើកស្ទួយ និងរក្សាលំនឹងជីវភាពរបស់ប្រជាពលរដ្ឋ ក្នុងស្ថានការណ៍ដ៏លំបាកក្រោមរូបភាពផ្សេងៗ ដូចជា វិធានការជំនួយសង្គម ក្នុងអំឡុងពេលនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងក្នុងអំឡុងពេលមានសម្ពាធអតិផរណា ជាដើម ។ បន្ថែមលើនេះ, រាជរដ្ឋាភិបាលក៏បានផ្តល់ការថែទាំសុខភាពដោយឥតគិតថ្លៃ តាមរយៈមូលនិធិសមធម៌សុខាភិបាល ជូនក្រុមអាទិភាព ដូចជា កម្មករក្រៅប្រព័ន្ធ, បុគ្គលិកបម្រើការក្នុងសេវាកម្មខ្នាតទេសចរណ៍, អ្នកជាក់ស៊ីក្លូ, កីឡាករជម្រើសជាតិ, សមាជិកក្រុមប្រឹក្សាភូមិឃុំ និងក្រុមគ្រួសារជនពលីមរណៈ ។

បច្ចុប្បន្ននេះ, ដើម្បីឱ្យមានការគិតគូរគ្រប់ជ្រុងជ្រោយដល់សេដ្ឋកិច្ចក្រៅប្រព័ន្ធ, **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានផ្តល់ការណែនាំដ៏ខ្ពង់ខ្ពស់ឱ្យគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

និងក្រសួង-ស្ថាប័នពាក់ព័ន្ធ រៀបចំ **យុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ ២០២៣-២០២៨** សំដៅបង្កលក្ខណៈងាយស្រួល ក្នុងការឈានចូលក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ព្រមទាំងផ្តល់ការគាំពារ និងលើកស្ទួយកម្រិតជីវភាពរស់នៅរបស់អ្នកប្រកបមុខរបរ និងធ្វើការងារ និង សហគ្រាសធុនមីក្រូ, តូច និងមធ្យម នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងពង្រឹងសមត្ថភាព ដើម្បីអាចទទួលបានការគាំទ្រផ្សេងៗ ដូចជា ការ-ពង្រីកវិសាលភាពនៃកម្មវិធីជំនួយសង្គម, ការផ្តល់ការបណ្តុះបណ្តាលជំនាញ, លទ្ធភាពទទួលបានហិរញ្ញ-ប្បទានជាដើម ។

ក្នុងស្មារតីនេះ, ការផ្តល់សេវារដ្ឋបាលខាងលើ នឹងត្រូវបានគិតគូរឡើងវិញ បន្ទាប់ពីយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ ២០២៣-២០២៨ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត ។